ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ៧០៤ គ.ជ.ប

# គោលការណ៍
## សម្រាប់
## សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ស្តីពីការរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្សនយោបាយក្នុងអំឡុងពេលឃោសនាបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣

- យោងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- យោងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមកំណត់នូវគោលការណ៍សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្សដើម្បីផ្សព្វផ្សាយក្នុងអំឡុងពេលឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ដូចខាងក្រោម៖

### ១. កិច្ចសហការជាមួយ គ.ជ.ប
#### ១.១ ការពិគ្រោះយោបល់

សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលមានបំណងរៀបចំកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចពិគ្រោះយោបល់ជាមួយគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយកម្មវិធីគោលនយោបាយរបស់គណបក្សនយោបាយ "គណៈកម្មការសម្របសម្រួល" មុននឹងចាប់ផ្តើមធ្វើកម្មវិធីនេះ លើបញ្ហាមួយចំនួនដូចជា៖

- លក្ខណៈបច្ចេកទេសដែលត្រូវរៀបចំធ្វើ
- ប្រធានបទ ឬសំណួរដែលត្រូវដាក់ជូនគណបក្សនយោបាយ



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

- ការសម្របសម្រួលទីតាំងប្រជុំ សន្តិសុខ សុវត្ថិភាព និងវិធានការសុខាភិបាល (ការការពារជំងឺកូវីដ-១៩)។

## ១.២ ការទទួលខុសត្រូវ

សាមីសមាគម អង្គការ ឬប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលរៀបចំកម្មវិធី ត្រូវទទួលខុសត្រូវលើខ្លឹមសារផ្សព្វផ្សាយគោលនយោបាយនេះ និងទទួលបន្ទុករាល់ការចំណាយទាំងអស់។

## ២. កិច្ចដំណើរការកម្មវិធី

កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវធ្វើឡើងជាមួយគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣។ កម្មវិធីនេះអាចធ្វើនៅទីសាធារណៈ ឬកន្លែងឯកជនតាមមូលដ្ឋាន ឬនៅថ្នាក់ជាតិ និងតាមស្ថានីយវិទ្យុ ឬទូរទស្សន៍ផ្ទាល់។ ដើម្បីឱ្យដំណើរការកម្មវិធីសំណួរចម្លើយ ឬពិភាក្សានេះ ប្រព្រឹត្តទៅមានភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយដែលចូលរួមការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

## ២.១ ការត្រៀមរៀបចំមុនកម្មវិធីចាប់ផ្តើមដំណើរការ

- ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរអញ្ជើញតំណាងគណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ជាផ្លូវការ ដើម្បីឱ្យចាត់តាំងតំណាងរបស់ខ្លួនចូលរួមក្នុងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា។
- យោងតាមកម្រិតនៃការរៀបចំនៅតាមមូលដ្ឋាន ឬនៅថ្នាក់ជាតិ ការធ្វើលិខិតអញ្ជើញនេះ ត្រូវអញ្ជើញគ្រប់គណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមមណ្ឌលរាជធានី ខេត្ត ឬគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ នេះ។
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលមានបំណងរៀបចំកម្មវិធីនៅតាមរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាឱ្យគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅតាមរាជធានី ខេត្ត ឬនៅទូទាំងប្រទេស បានចូលរួម។
- ត្រូវផ្តល់ប្រធានបទ និងសំណួរដែលត្រូវចោទសួរក្នុងកម្មវិធីសំណួរចម្លើយ ឬពិភាក្សាជូនគណបក្សនយោបាយយ៉ាងតិច ១០ (ដប់) ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី។
- ក្នុងករណីដែលគណបក្សនយោបាយបានទទួលលិខិតអញ្ជើញនោះហើយ តែពុំបានចាត់តំណាងរបស់ខ្លួនឱ្យទៅចូលរួមក្នុងកម្មវិធីតាមកាលបរិច្ឆេទកំណត់ មានន័យថាគណបក្សនយោបាយនោះ បោះបង់ចោលពេលវេលារបស់ខ្លួន ហើយកម្មវិធីនឹងត្រូវដំណើរការធម្មតាទៅតាមកាលបរិច្ឆេទកំណត់។

## ២.២ ទីកន្លែងដំណើរការកម្មវិធី និងសមាសភាពចូលរួម

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅទីសាធារណៈ ឬកន្លែងឯកជននៅតាមរាជធានី ខេត្ត។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចធ្វើនៅស្ថានីយវិទ្យុ ឬទូរទស្សន៍នៅក្នុងរាជធានី ខេត្ត។
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចអញ្ជើញប្រជាពលរដ្ឋចូលរួមស្តាប់ និងចោទសំណួរបាន ប្រសិនបើអ្នកគ្រប់គ្រងកម្មវិធីចង់ឱ្យមាន។

## ២.៣ អ្នកសម្របសម្រួលកម្មវិធី

អ្នកសម្របសម្រួលកម្មវិធីសំណួរចម្លើយ ឬពិភាក្សា ត្រូវប្រកាន់ជំហរអព្យាក្រឹត យុត្តិធម៌ និងមានសមត្ថភាពក្នុងការគ្រប់គ្រងកិច្ចដំណើរការកម្មវិធីឱ្យបានល្អ និងសុវត្ថិភាព។

## ២.៤ ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬពិភាក្សាតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម

កម្មវិធីសំណួរចម្លើយ ឬពិភាក្សាអំពីគោលនយោបាយរបស់គណបក្ស ដែលត្រូវផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងបណ្តាញសង្គម ត្រូវបានអនុវត្តដូចខាងក្រោម៖

- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា ដែលធ្វើនៅតាមរាជធានី ខេត្តណាមួយ អាចធ្វើការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ដែលមានស្ថានីយនៅក្នុងរាជធានី ខេត្តនោះ និងតាមបណ្តាញសង្គម
- កម្មវិធីសំណួរចម្លើយ ឬពិភាក្សា អាចផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍នៅថ្នាក់ជាតិ និងបណ្តាញសង្គមបាន លុះត្រាតែអនុវត្តតាមចំណុច ២.១ ខាងលើនេះ។

# ៣. គោលការណ៍អនុវត្ត

- អ្នកគ្រប់គ្រងកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្សត្រូវតែអព្យាក្រឹត និងមិនលម្អៀង
- ការផ្សព្វផ្សាយកម្មវិធីសំណួរចម្លើយ ឬពិភាក្សា អំពីគោលនយោបាយរបស់គណបក្ស ពុំតម្រូវឱ្យមានលិខិតយល់ព្រមពី គ.ជ.ប ឡើយ។ ប៉ុន្តែអ្នកគ្រប់គ្រងកម្មវិធីនេះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ក្នុងករណីមានកំហុសលើដំណើរការនៃការផ្សាយកម្មវិធី
- សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវគោរពច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងគោលការណ៍នេះ។

ថ្ងៃសុក្រ ៤ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**